# ប្រកាសលេខ

# ២៨៤

# ស្តីពីការបង្កើតអង្គ

# ភាពពលករ

# បរទេស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សក MOSALVY

**ក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ ...១០៥៤.........សកបយ

ភ្នំពេញ,ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## ការបង្កើតអង្គភាពពលករបរទេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញ លិខិតលេខ ១ ១៦៦ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១ :** បង្កើត **អង្គភាពពលករបរទេស** ជាភាសាអង់គ្លេសហៅថា FOREIGN WORKER UNIT ស្ថិតនៅក្នុងអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីគ្រប់គ្រងពលករបរទេសទាំងអស់ នៅក្នុងព្រះរាជាណាចក្រ។

កម្ពុជា ដែលស្ថិតនៅក្រោមបទបញ្ញត្តិ នៃច្បាប់ស្តីពីការងារ ។

**ប្រការ ២:** **អង្គភាពពលករបរទេស** ជាអង្គភាពអន្តរនាយកដ្ឋានពាក់ព័ន្ធ មានតួនាទីសម្របសម្រួល និងផ្តល់សេវាកម្ម ចំពោះសហគ្រាសគ្រឹះស្ថាននានា ដែលប្រើប្រាស់ជនបរទេស និងជួយបង្កើនប្រសិទ្ធិភាព នៃការគ្រប់គ្រងពលករបរទេស របស់នាយកដ្ឋានមុខរបរនិងហត្ថពលកម្ម នាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ និងនាយកដ្ឋានពេទ្យការងារ ។

អង្គភាពពលករបរទេស មានភារកិច្ច ដូចតទៅ :

១-ផ្តល់សេវាក្នុងការងារសុំកូតា ការស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស រៀបចំកិច្ចសន្យាការងាររវាងជនបរទេសនិងនិយោជក រៀបចំបែបបទសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចេញ និងចូល ។

២-ផ្តល់សេវានៃការស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារថ្មីនៃជនបរទេស និងពន្យាសុពលភាពនៃប័ណ្ណ និងសៀវភៅ ។ ទទួលអាករប័ណ្ណការងារ និងសៀវភៅការងារ និងបង់ ចូលថវិការដ្ឋ តាមការកំណត់របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

៣-សហការជាមួយក្រសួងមហាផ្ទៃ តំណាងការងារទូតប្រទេសដើមរបស់ពលករបរទេស និងសមាគមនិយោជក និងនិយោជក ដើម្បីដោះស្រាយរាល់ការងារដែលពាក់ព័ន្ធជាមួយជនបរទេស ។

៤-គ្រប់គ្រងការងារអធិការកិច្ចហត្ថពលកម្មបរទេស និងទំនាក់ទំនងវិជ្ជាជីវៈរវាងពលករបរទេស និងនិយោជក ។

**ប្រការ ៣ :** បង្កើតលេខាធិការដ្ឋានមួយនៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ជាជំនួយការរបស់ **អង្គភាពពលករបរទេស** ដែលមានមន្ត្រីជំនាញបំរើការមកពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ។

សមាសភាពមន្ត្រីនៃលេខាធិការដ្ឋានរួមមាន:

| | | |
|---|---|---|
| ១-លោក ហ៊ូ វុឌ្ឍី | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២-លោក សេង សក្កដា | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | អនុប្រធាន |
| ៣-លោក ឃួន ឡានិច | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ៤-លោក ស្រេង ជូឡុង | ប្រធានការិយាល័យស្ថិតិមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ៥- លោក ឆាំង ហាក់យូ | អនុប្រធានការិយាល័យត្រួតពិនិត្យជនបរទេស | សមាជិក |
| ៦-លោក អ៊ឹង រ័ត្នធីណា | អនុប្រធានការិយាល័យត្រួតពិនិត្យជនបរទេស | សមាជិក |
| ៧-លោក ឃុន ពិសិដ្ឋា | មន្ត្រីការិយាល័យត្រួតពិនិត្យជនបរទេស | សមាជិក |
| ៨-លោក ជូរ រតនៈ | មន្ត្រី នាយកដ្ឋានពេទ្យការងារ | សមាជិក |

៥-លោក ជួន ឃុន មន្ត្រីនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈនិងទីផ្សារការងារ សមាជិក

មន្ត្រី ដែលត្រូវបានចាត់តាំងឱ្យទទួលភារកិច្ច នៅក្នុងលេខាធិការដ្ឋាននៃ **អង្គភាពពលករបរទេស** ត្រូវបានរក្សាក្របខ័ណ្ឌ បៀវត្ស ការដំឡើងឋានៈ និងការលើកសរសើរនៅអង្គភាពដើម ។

**ប្រការ ៤:** អង្គភាពពលករបរទេស ត្រូវសហការឱ្យបានល្អជាមួយ នាយកដ្ឋានជនបរទេស នៃអគ្គនាយកដ្ឋានទគរបាលជាតិ នៃក្រសួងមហាផ្ទៃ ក្នុងដំណើរការអនុវត្តនីភារកិច្ចដែលពាក់ព័ន្ធ ។

**ប្រការ ៥:** ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកដ្ឋានមុខរបរ និងបាត្តពលកម្ម នាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ និង នាយកដ្ឋានពេទ្យការងារ និង មន្ត្រីដែលទទួលភារកិច្ច នៅក្នុងប្រការ៣ ត្រូវអនុវត្តប្រកាសនេះប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-សមាគមនិយោជក នៃព្រះរាជាណាចក្រកម្ពុជា

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៣ និងប្រការ ៥

" ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ